ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៥៦/២២ អអរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តស្វាយរៀង"

ព្រឹកថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តស្វាយរៀង»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម ជុំ ហាត ប្រធានក្រុមប្រឹក្សាខេត្ត**
- **លោក សុខ សំអន មេឃុំស្វាយយា ស្រុកស្វាយជ្រុំ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបំផុស និងបង្ហាញជាសាធារណៈ នូវយន្តការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាប្រវត្តិសាស្ត្ររបស់កម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងកិច្ចរក្សាបាននូវការជឿទុកចិត្ត ចូលរួម និងគាំទ្រពីប្រជាពលរដ្ឋ តាមយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

## I. សេចក្តីផ្តើម

ខេត្តស្វាយរៀង មានប្រជាពលរដ្ឋសរុបចំនួន ៦៥៣.៧៦៦នាក់ ស្រី ៣៣៦.៦៣៨នាក់ ស្មើនឹង ១៥៦.០៥១គ្រួសារ ក្នុងនោះប្រជាជនភាគច្រើនប្រកបមុខរបរកសិកម្ម ប្រមាណ៥៨% ឧស្សាហកម្ម និងសេវាកម្ម ៤០% និងមុខរបរសិប្បកម្មប្រមាណ២%។ ខេត្តមានតំបន់សេដ្ឋកិច្ចពិសេសចំនួន១២កន្លែង កំពុងដំណើរការ ៩កន្លែង សរុបទូទាំងខេត្ត មានក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានឯកជន ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សរុបចំនួន ២៤៧កន្លែង បង្កើតការងារធ្វើជូនប្រជាពលរដ្ឋប្រមាណ ៩៥.៤៧០នាក់ ក្នុងនោះកម្មករ កម្មការិនី នៅតាមរោងចក្រ សហគ្រាស មានចំនួន ៦ម៉ឺននាក់។

## II. វឌ្ឍនភាពការងារសំខាន់ៗ

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តស្វាយរៀង បានអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន តាមរយៈអង្គប្រជុំក្នុងការចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីជានាលើការផ្តល់សេវា និងការអភិវឌ្ឍជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ប្រសិទ្ធភាព ដោយឈរលើគោលការណ៍អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងការបំពេញមុខងារ ភារកិច្ច ដែលរាជរដ្ឋាភិបាល បានប្រគល់ និងបានធ្វើប្រតិភូកម្មជូនតាមច្បាប់គតិយុត្ត។

ក្រុមប្រឹក្សាខេត្ត បានធ្វើសេចក្តីសម្រេច ដីកា វិធានការ គោលការណ៍ គោលនយោបាយ ផែនការអភិវឌ្ឍ ៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកាប្រចាំឆ្នាំ និងការដោះស្រាយតម្រូវការជាក់លាក់បន្ទាន់សំដៅជំរុញ កសាង និងអភិវឌ្ឍខេត្ត ធ្វើឱ្យខេត្តស្វាយរៀងមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសលើវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្រុមប្រឹក្សាខេត្ត ក៏បានដឹកនាំ ជំរុញ ត្រួតពិនិត្យ និងចូលរួមក្នុងការងារសំខាន់ៗមួយចំនួនទៀត មានដូចជា៖

- ការសាងសង់អាគាររដ្ឋបាលឃុំ សង្កាត់ ជួសជុលផ្លូវថ្នល់ ប្រព័ន្ធលូរំដោះទឹក និងការកែលម្អសោភណ្ឌភាពក្រុង ស្រុក។
- កម្មវិធីអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ ស្ត្រីមានផ្ទៃពោះ កុមារ និងជនងាយរងគ្រោះក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩។
- ការចុះអប់រំផ្សព្វផ្សាយអំពីវិធានការការពារ និងបង្ការការឆ្លងជំងឺកូវីដ-១៩ និងចូលរួមក្នុងការបរិច្ចាកថវិកាជូនរាជរដ្ឋាភិបាល ក្នុងការទិញវ៉ាក់សាំង កូវីដ-១៩។

### ❖ ឃុំស្វាយយា ស្រុកស្វាយជ្រំ

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាឃុំសម្រេចបានរួមមាន៖

- បានកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុងសរុប២ខ្សែ ជួសជុលផ្លូវក្រាលគ្រួសក្រហម និងសាងសង់របងសាលារៀន ក្រាលការ៉ូ ចាក់សាប ធ្វើបន្ទប់ទឹក បង្គោលភ្លើង និងរបងប៉ុស្តិ៍នៅក្នុងឃុំ។
- បានរៀបចំកម្លាំងប្រជាការពារតាមភូមិទាំង១៥ភូមិ ដោយសហការជាមួយកម្លាំងប៉ុស្តិ៍រដ្ឋបាលសហគមន៍ឃុំ ចុះការពារសន្តិសុខជូនប្រជាពលរដ្ឋក្នុងពិធីបុណ្យទានតាមវត្តអារាម និងពិធីផ្សេងៗនៅតាមមូលដ្ឋាន។
- បានចុះធ្វើវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាព ផ្សព្វផ្សាយវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ តាមភូមិ វត្តអារាម និងពិធីបុណ្យទាន ផ្សេងៗ និងទទួលយកនូវសំណូមពរ ឆ្លើយតបដោះស្រាយជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។
- បានបង្កើតសមាគមន៍មនុស្សចាស់មួយ មានសមាជិកចំនួន ៧៣៤នាក់ស្រី ៤៩៩នាក់។

- បានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងទាន់ពេលវេលា ព្រមទាំងបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ស្ត្រីមានផ្ទៃពោះ ជនពិការ កុមារ និងគ្រួសារងាយរងគ្រោះ ក្នុងអំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- បន្តកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា និងចូលរួមកិច្ចប្រជុំប្រចាំខែ ដើម្បីពិគ្រោះយោបល់ និងគាំទ្រក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាក្រុង-ស្រុក ឃុំ-សង្កាត់ ដែលបានធ្វើប្រតិភូកម្ម។
- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ របស់ក្រុមប្រឹក្សាខេត្ត ជាមួយប្រជាពលរដ្ឋតាមបណ្តាក្រុង-ស្រុក ដើម្បីប្រមូលនូវបញ្ហាប្រឈម និងសំណូមពររបស់ប្រជាពលរដ្ឋ
- បន្តតាមដាន ត្រួតពិនិត្យ នូវការអនុវត្តផែនការ ឱ្យសម្រេចបានលទ្ធផលល្អ តាមរយៈផែនការអភិវឌ្ឍ កម្មវិធីវិនិយោគខេត្ត
- បន្តជំរុញយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- បន្តដាក់ចេញនូវវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ កុំឱ្យមានការរីករាលដាលដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ការអនុវត្តវិធានការ ៣កុំ និង៣ការពារ។
- បន្តជំរុញការគាំទ្រ និងតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារ នៃគ្រួសារក្រីក្រ ព្រមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងចំគោលដៅ។

### ❖ ឃុំស្វាយយា ស្រុកស្វាយជ្រំ

- បន្តពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋ និងបន្តផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។
- បន្តចុះធ្វើវេទិកាសាធារណៈ ភូមិឃុំមានសុវត្ថិភាព ៧ ចំណុចដល់ប្រជាពលរដ្ឋបានជាប្រចាំ
- បន្តទំនាក់ទំនងក្រុមការងារ មន្ទីរវិស័យសប្បុរសជន អង្គការដៃគូរ មកជួយអភិវឌ្ឍន៍មូលដ្ឋាន
- បន្តចុះផ្សព្វផ្សាយវិធានការសុខាភិបាល ជំរុញការចាក់វ៉ាក់សាំង ការទប់ស្កាត់ជំងឺកូវីដ-១៩
- បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ កុមារ និងគ្រួសារក្រីក្រ
- បន្តខិតខំដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ជូនប្រជាពលរដ្ឋ។

## IV. សម្គាល់

- ការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល(ODF) នៅក្នុងខេត្តស្វាយរៀង គឺសម្រេចបាន ១០០% ដោយមានការសហការល្អពីក្រុមការងារអនាម័យជនបទថ្នាក់ខេត្ត ក្រុង ស្រុក ក្នុងការផ្សព្វផ្សាយតាមខ្នងផ្ទះ មានការលើកទឹកចិត្តដល់អ្នកអនុវត្តផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ និងបានធ្វើបច្ចុប្បន្នភាពសៀវភៅទិន្នន័យអនាម័យ បានជំរុញ និងលើកទឹកចិត្តឱ្យសាងសង់ និងការស្វែងរកការគាំទ្រពីអង្គការដៃគូក្នុងការឧបត្ថម្ភធនជាន ព្រមទាំងមានការពង្រឹងសមត្ថភាពដល់មន្រ្តីថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការចុះ ធ្វើការអប់រំ ផ្សព្វផ្សាយ និងការកត់ត្រា។

- នៅក្នុងខេត្តស្វាយរៀង គឺមានច្រកទ្វារអន្តរជាតិ សម្រាប់នាំទំនិញចេញ-ចូល។ ក្នុងអំឡុងពេលនៃមានការរីករាលដាលនៃជំងឺកូវីដ-១៩ ស្ថានភាពសេដ្ឋកិច្ចនៅក្នុងខេត្តស្វាយរៀង នៅតែមានសន្ទុះដោយច្រកព្រំដែនអន្តរជាតិនៅតែបើកដំណើរការ ប៉ុន្តែក្នុងការដោះដូរទំនិញ ត្រូវតែអនុវត្តតាមវិធានសុខាភិបាល។ ជាក់ស្តែងនៅមុនពេលមានបញ្ហាកូវីដ-១៩ ទំហំនៃការនាំចេញមាន ២៦,៧៦៥,៩០១ ដុល្លារ ហើយនៅក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ទំហំនៃការនាំចេញ មានការកើនឡើងដល់ ៤១,៩៩៨,៩៤៣ដុល្លារ។៕

ថ្ងៃព្រហស្បតិ៍ ២កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២